ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

១៥៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលអនុក្រឹត្យលេខ២៩អនក្រ .បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីថ្លៃអាករលើឯកសារធ្វើដំណើរ លិខិតបើកផ្លូវ ប័ណ្ណស្នាក់នៅបណ្តោះអាសន្ន និង ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ សម្រាប់ជនបរទេសអន្តោប្រវេសន្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ / នស /៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៥ ន/ស /៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីថ្លៃអាករលើឯកសារធ្វើដំណើរ លិខិតបើកផ្លូវ ប័ណ្ណស្នាក់នៅបណ្តោះអាសន្ន និងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ សម្រាប់ជនបរទេសអន្តោប្រវេសន្ត
- ចំណារឯកភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១០
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១** : ត្រូវបានកំណត់អាករលើលិខិតធ្វើដំណើរដូចខាងក្រោម:

ក-ឯកសារធ្វើដំណើរ ចំនួន ៣០០.០០០៛០០ ( បីរយពាន់រៀល ) ។

ខ-លិខិតបើកផ្លូវ ចំនួន ៥០.០០០៛០០ ( ហាសិបពាន់រៀល ) ។

**មាត្រា២** : ត្រូវបានកំណត់អាករលើការពន្យារលិខិតធ្វើដំណើរដូចខាងក្រោម:

ក-ការពន្យារពេលឯកសារធ្វើដំណើរ ចំនួន ២៥.០០០រ០០ ( ម្ភៃប្រាំពាន់រៀល ) ។

ខ-ការពន្យារពេលលិខិតបើកផ្លូវ ចំនួន ១៩.០០០រ០០ ( ដប់ប្រាំបួនពាន់រៀល ) ។

**មាត្រា៣** : ត្រូវបានអនុញ្ញាតឲ្យរួចអាករចំពោះកុមារទាំងពីរភេទមានអាយុ១២ឆ្នាំចុះ ដែលរួមដំណើរជាមួយឪពុក ម្តាយ ឬអាណាព្យាបាល ។

**មាត្រា៤** : ត្រូវបានកំណត់អាករលើប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ដូចខាងក្រោម:

ក-ប័ណ្ណស្នាក់នៅបណ្តោះអាសន្ន ( មានសុពលភាព១ឆ្នាំជាអតិបរមា ) ចំនួន២៥០.០០០រ០០ ( ពីររយហាសិបពាន់រៀល ) ។

ខ-ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ចេញឲ្យលើកដំបូងមានសុពលភាព២ឆ្នាំ ចំនួន២៥០.០០០រ០០ ( ពីររយហាសិបពាន់រៀល ) ។

គ-ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ទុតិយតា មានសុពលភាព២ឆ្នាំ ចំនួន ២៥០.០០០រ០០ ( ពីររយហាសិបពាន់រៀល ) ។

**មាត្រា៥** : ត្រូវបានកំណត់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍អាចសុំពន្យារពេល២ឆ្នាំម្តង ចំនួន២៥០.០០០រ០០ ( ពីររយហាសិបពាន់រៀល ) ។

**មាត្រា៦** : ថ្លៃអាករគ្រប់ប្រភេទខាងលើនេះ ត្រូវបង់ចូលថវិកាជាតិ

-បែបបទនៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ។

**មាត្រា៧** : អនុក្រឹត្យលេខ២៩ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីថ្លៃអាករលើឯកសារធ្វើដំណើរ លិខិតបើកផ្លូវ ប័ណ្ណស្នាក់នៅបណ្តោះអាសន្ន ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ សំរាប់ជនបរទេសអន្តោប្រវេសន្ត ត្រូវទុកជានិរាករណ៍ ។

**មាត្រា៨** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៩** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា៩
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ